# កៅស៊ូក្នុងនាមទំនិញសេដ្ឋកិច្ច

ខែសីហា ឆ្នាំ២០១០

អនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម

នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)

ទីស្តីការគណៈរដ្ឋមន្ត្រី

# មាតិកា


| | ទំព័រ |
|---|---|
| បញ្ជីរតារាង………………………………………………………………………… | ii |
| បញ្ជីររូប………………………………………………………………………… | ii |
| ១. សេចក្តីផ្តើម………………………………………………………………… | ១ |
| ២. ចំការកៅស៊ូនៅព្រះរាជាណាចកកម្ពុជា………………………………………… | ១ |
| ២.១ កម្មសិទ្ធ ……………………………………………………………… | ១ |
| ២.២ មូលដ្ឋានធនធាន……………………………………………………… | ២ |
| ២.៣ ផលិតកម្មកៅស៊ូ………………………………………………………… | ៤ |
| ២.៤ ការប្រមូលនិងពាណិជ្ជកម្មកៅស៊ូ ……………………………………… | ៩ |
| ២.៥ ដំណើរការកែច្នៃកៅស៊ូ ……………………………………………… | ១០ |
| ២.៦ ការនាំចេញកៅស៊ូ ……………………………………………………… | ១០ |
| ២.៧ ការចំណាយ និងផលចំណេញ……………………………………………… | ១៤ |
| ៣. បញ្ហាប្រឈម និងឧបសគ្គ………………………………………………… | ១៤ |
| ៤. សក្តានុពលភាព………………………………………………………………… | ១៧ |
| ៥. ការគំរាមកំហែង……………………………………………………………… | ១៧ |
| ៦. អនុសាសន៍………………………………………………………………… | ១៨ |
| ៧. សេចក្តីសន្និដ្ឋាន…………………………………………………………… | ១៩ |
| ឯកសារយោង………………………………………………………………… | ២១ |
| ការសម្ភាសន៍………………………………………………………………… | ២២ |

## បញ្ជីតារាង

| | ទំព័រ |
|---|---|
| តារាង ១: ការបែងចែកដីក្រហម | ៣ |
| តារាង ២: ផលិតផល និងផលិតភាពកៅស៊ូ(១៩២៨-១៩៦៦) | ៦ |
| តារាង ៣: ចំការកៅស៊ូកម្ពុជា ១៩៨០-២០០៩ | ៧ |
| តារាង ៤: ផលិតផល និងផលិតភាពតាមចំការ២០០៨ –២០០៩ | ៨ |
| តារាង ៥: បរិមាណ និងតំលៃនៃការនាំកៅស៊ូចេញរបស់កម្ពុជា | ១១ |
| តារាង ៦: ការនាំចេញកៅស៊ូធម្មជាតិ | ១៣ |
| តារាង ៧: ការប្រៀបធៀបចំណាយក្នុងតំបន់នៃការនាំចេញ | ១៥ |

## បញ្ជីរូប

| | ទំព័រ |
|---|---|
| រូបទី១ : ខ្សែចង្វាក់ផលិតកម្មកៅស៊ូ | ៩ |

## ១. សេចក្តីផ្តើម

ដំណាំកៅស៊ូ គឺជាដំណាំសេដ្ឋកិច្ចរយៈពេលវែង។ ដំណាំនេះផ្តល់ប្រាក់ចំណូលដល់រូបវន្តបុគ្គល ក្រុមហ៊ុនឯកជន និងរដ្ឋាភិបាល។ ដំណាំនេះបង្កើតការងារដល់ សហគមន៍ជនបទ និងមិនជំរុញកសិករឲ្យផ្លាស់ប្តូរទីលំនៅមកនៅទីប្រជុំជន។ ការដាំដំណាំនេះ ជួយការពារបរិស្ថាន ការពារដីមិនឲ្យហូរច្រោះ និងបង្ការមិនឲ្យខូចជីវជាតិដីទៀតផង។

រហូតដល់អំឡុងឆ្នាំ២០០១ ផលិតផលកៅស៊ូបានធ្លាក់ចុះគួរឲ្យកត់សំគាល់ ដោយសារដើមកៅស៊ូភាគច្រើនមានអាយុកាលជាង៥០ឆ្នាំហើយ។ បើយោងតាមលក្ខខណ្ឌដីអំណោយផលនៅខេត្តកំពង់ចាម ក្រចេះ កំពង់ធំ រតនៈគិរី និងខេត្តមណ្ឌលគិរី គេអាចពង្រីកផ្ទៃដីដាំដុះរហូតដល់ជិត៣៣០,០០០ហិចតា រីឯទិន្នផលវិញអាចនឹងផ្តល់ជាកៅស៊ូស្ងួតប្រហែល ៥០០,០០០តោនក្នុងមួយឆ្នាំ។

## ២. ចំការកៅស៊ូនៅព្រះរាជាណាចក្រកម្ពុជា

### ២.១ កម្មសិទ្ធ

នៅព្រះរាជាណាចក្រកម្ពុជា ចំការកៅស៊ូត្រូវបានបែងចែកជាបីប្រភេទកម្មសិទ្ធៈ

**ក. ចំការកៅស៊ូរដ្ឋៈ** ភាគច្រើនស្ថិតក្នុងខេត្តកំពង់ចាមដែលមាន៦៣%នៃផ្ទៃដីចំការកៅស៊ូសរុប និងបានគ្រប់គ្រងដោយក្រុមហ៊ុនរដ្ឋទាំង៧។ ដើម្បីលើកស្ទួយកំរិតជីវភាពម្ចាស់ចំការកៅស៊ូខ្នាតតូច និងមធ្យម នៅចុងខែវិច្ឆិការឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩នេះ រដ្ឋាភិបាលបានប្រែក្លាយចំការរដ្ឋទាំងនោះទៅជារបស់កម្មសិទ្ធឯកជនវិញ។

**ខ.ចំការកៅស៊ូគ្រួសារ(កម្មសិទ្ធករខ្នាតតូច)**: គឺជាប្រភេទចំការដែលមានក្រឡាផ្ទៃតិចជាង២០ហិចតា អភិវឌ្ឍន៍ដោយកសិករអ្នកមាន វិនិយោគិនខ្នាតតូច និងមធ្យមដែលរស់នៅតំបន់នោះ(ម្ចាស់ស្រុក) និងដោយកសិករក្រីក្រតិចតួចខ្លះៗ។ ប្រភេទចំការកៅស៊ូគ្រួសារនេះបានរីកយ៉ាងលឿនរហ័ស ដោយសារគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ដោយបង្កើតការងារនៅតំបន់ជនបទ និងការពារបរិស្ថាន ជាពិសេសបង្ការមិនឲ្យខូចដី។ ដោយមានការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍( FAD) ចំការប្រភេទនេះត្រូវបានបង្កើតឡើងនៅខេត្តកំពង់ចាមចាប់ពីឆ្នាំ១៩៩៩មក។

**គ. ចំការកៅស៊ូឯកជនៈ** ជាប្រភេទចំការដែលមានផ្ទៃដីចាប់ពី២០រហូតដល់២ទៅបីពាន់ហិចតាដែលអភិវឌ្ឍដោយវិនិយោគិនថ្មីៗ។ ក្នុងចំណោមវិនិយោគិនទាំងនោះមាន អ្នក

នៅក្នុងខេត្ត និងជាអ្នកមានមកពីភ្នំពេញភាគច្រើន។ បច្ចុប្បន្ននេះ ចំការកៅស៊ូឯកជនមួយចំនួនតូច ស្ថិតនៅក្នុងតំបន់ចាស់ដដែលដូចជានៅក្នុងខេត្តកំពង់ចាម ក្រចេះ កំពង់ធំ ចំណែកឯមួយភាគធំនៃចំការដែលបង្កើតថ្មីស្ថិតនៅក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី។ ក្រៅពីនេះមានការប៉ុនប៉ងបង្កើតចំការកៅស៊ូថ្មីផ្សេងទៀតនៅភាគខាងជើង និងភាគខាងលិច គឺក្រៅពីតំបន់ដែលធ្លាប់ដាំដុះដើមកៅស៊ូ ប៉ុន្តែគេនៅមិនទាន់ដឹងច្បាស់អំពីភាពដែលអាចធ្វើបានទាក់ទងនឹងបញ្ហាបច្ចេកទេស និងសេដ្ឋកិច្ច។

គួរឲ្យកត់សំគាល់ថា ចាប់ពីឆ្នាំ១៩៩២មក ផ្ទៃដីជិត៩០៩,០០០ហិចតា ត្រូវបានសម្រេចឲ្យស្ថិតក្រោមគម្រោងសម្បទាន៥០គម្រោងដើម្បីធ្វើការអភិវឌ្ឍវិស័យកសិកម្ម។ ក្នុងនោះជិត ១៣%(ប្រហែល១២០,០០០ហិចតា) ត្រូវបានផ្តល់ដោយឡែកសម្រាប់សម្បទានិកចំនួន២៥ដែលធ្វើការដាំដុះដំណាំកៅស៊ូ។ យោងតាមពត៌មានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គម្រោងសម្បទានភាគច្រើនមានផ្នែកខ្លះគ្របដណ្តប់ដោយព្រៃធម្មជាតិ។ បានន័យថាត្រូវសំអាតព្រៃឈើទាំងនោះដើម្បីដាំដំណាំកៅស៊ូវិញ។ ជាលទ្ធផលធ្វើឲ្យមានកើតបញ្ហាចំរូងចំរាស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីមានការប្រែប្រួល និងបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងការចំណាយ និងផលចំណេញសេដ្ឋកិច្ច ព្រមទាំងការជះឥទ្ធិពលទៅលើសង្គម និងបរិស្ថានដោយសារតែបម្រែបម្រួលនេះ។

## ២.២ មូលដ្ឋានធនធាន

កៅស៊ូមានដើមកំណើតចេញពីតំបន់អេក្វាទ័រនៃអាងអាម៉ាសូន ក្រោមលក្ខខណ្ឌសំណើមត្រូពិក។ ចំការកៅស៊ូតម្រូវឲ្យមានសីតុណ្ហភាពមធ្យមប្រហែល ២៥$^{0}$ C និងសីតុណ្ហភាពទាបបំផុត ១៥$^{0}$ C ។ កំពស់ទឹកភ្លៀងមធ្យម ១៥០០មម/ឆ្នាំ ជាមួយនឹងរដូវស្ងួតរយៈពេលខ្លី ជាការល្អសម្រាប់កៅស៊ូ។ កំពស់ដីដាំកៅស៊ូបានល្អបំផុត គឺ មិនត្រូវលើសពី ៤០០មធៀបទៅនឹងនីវូសមុទ្រ។ មិនគួរដាំកៅស៊ូនៅក្នុងតំបន់ដែលមានខ្យល់ខ្លាំង។កៅស៊ូអាចដាំលើដីទួល ប៉ុន្តែជាការល្អបើដាំវាលើដីទំនាប។ ជំរៅដី(ពី១.២០ម ទៅ១.៥០ម)ដែលមានទំហំផ្ទុកទឹកខ្ពស់ជាការប្រសើរ។

អាកាសធាតុម៉ូសុងត្រូពិចនៅកម្ពុជាមានពីររដូវ គឺរដូវវស្សា និងរដូវប្រាំង។ វាលទំនាបកណ្តាល និងផ្នែកខាងកើតនៃប្រទេសដែលមានចំការកៅស៊ូច្រើន មានកំពស់ទឹកភ្លៀងពី ១០០០ ទៅ២៨០០មម/ឆ្នាំ។ រដូវរាំងស្ងួតយូរអង្វែងធ្វើឲ្យរំខានដល់ផលិតផលកៅស៊ូ ប៉ុន្តែលើកលែងតែនៅលើដីដែលមានទំហំផ្ទុកទឹកខ្ពស់ប៉ុណ្ណោះដែលអាចកាត់បន្ថយឥទ្ធិពលនៃរដូវរាំង

ស្វូតនេះ។ ជាក់ស្តែងកម្ពុជាមានតំបន់ដីក្រហម(basaltic)យ៉ាងធំជាមួយនឹងទំហំផ្ទុកទឹកខ្ពស់។ ដីនេះផ្តល់សក្តានុពលទិន្នផលខ្ពស់សម្រាប់ដំណាំកៅស៊ូ។ នៅកម្ពុជាដីក្រហមបានលាតសន្ធឹងជាង ៧០០,០០០ហិចតា និងត្រូវបានបែងចែកដូចខាងក្រោម:

**តារាង១: ការបែងចែកដីក្រហម**

| តំបន់ | ផ្ទៃក្រឡា |
|---|---|
| តំបន់ទំនាបទន្លេមេគង្គ: | ហិចតា |
| ជប់ ត្រពាំងក្រៀល | 58,400 |
| ឆ្លូង មេមត់ | 57,400 |
| ចំការលើ | 32,900 |
| ព្រែកកក់ | 29,400 |
| ស្នួល | 8,500 |
| [redacted] | |
| ខ្ពង់រាបឥសាន: | |
| រតនៈគិរី | 180,000 |
| មណ្ឌលគិរី | 320,000 |
| ក្រចេះ | 20,000 |
| [redacted] | |
| តំបន់ដាច់ស្រយ៉ាលនៅភ្នំក្រវាញ | 10,000 |
| [redacted] | |

ប្រភព: Business Investment Handbook of Cambodia 1996

តំបន់ទំនាបទន្លេមេគង្គមានលក្ខណ:អំណោយផលចំពោះដំណាំកៅស៊ូ ហេតុដូចនេះហើយ បានជាចំការកៅស៊ូភាគច្រើនផ្តុំគ្នានៅក្នុងខេត្តកំពង់ចាម ក្រចេះ កំពង់ធំ។ ការពង្រីក សក្តានុពលក្នុងខេត្តមណ្ឌលគិរី រតនៈគិរី និងក្នុងខេត្តផ្សេងៗទៀតទាមទារនូវការយកចិត្តទុកដាក់ពិសេស ដោយសារជាតំបន់ខ្ពង់រាប មានសីតុណ្ហភាពទាប និងល្បឿនខ្យល់ខ្លាំងហើយញឹកញាប់ដែលជាឧបសគ្គដល់ការអភិវឌ្ឍដំណាំកៅស៊ូ។ ដើមកៅស៊ូទាមទារ៦ទៅ៧ឆ្នាំទើបចាប់ផ្តល់ផល។ ការចៀរយកជ័រកៅស៊ូចាប់ផ្តើមនៅឆ្នាំទី៥ទៅឆ្នាំទី៧ ហើយបន្តផ្តល់ផលពី២៥

ទៅ៣០ឆ្នាំទៀត។ បន្ទាប់ពីគិតរប់៣០ឆ្នាំ ដើមកៅស៊ូជាទូទៅត្រូវបានកាប់ចោល និងដាំកូនថ្មីជំនួសវិញ ដោយសារដើមកាន់តែចាស់ ជ័រកាន់តែខះមិនហៀរចេញ។ នៅអាយុកាលក្មេង ពេលដែលដើមកៅស៊ូមិនទាន់សម្បូរស្លឹក កសិករអាចដាំដំណាំទីផ្សារដែលទាមទាររយៈពេលខ្លីនៅចន្លោះដើមទាំងនោះដូចជា ដំឡូងមី និងប្រភេទផ្សេងៗនៃអំបូរសណ្តែក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការដាំដំណាំទីផ្សារនៅក្នុងចំការកៅស៊ូមិនអាចពន្យាពេលឲ្យលើសពី៣ទៅ៤ឆ្នាំបានទេ ពិព្រោះដើមកៅស៊ូចាប់ផ្តើមបិទបាំងពន្លឺព្រះអាទិត្យមិនឲ្យទៅដល់ដី។

មានប្រភេទដើមកៅស៊ូមួយចំនួនផ្សេងៗគ្នាត្រូវបានគេដាំ។ GT1បានបង្ហាញខ្លួនតាំងពីយូរមកហើយ ជាប្រភេទពេញនិយមជាងគេ បន្ទាប់មកបន្តដោយប្រភេទផ្សេងៗទៀត។ តាំងពីឆ្នាំ១៩៩៣ គំរូថ្មី( new clones )ត្រូវបានបង្ហាញ ដូចជា PB230, PB260, IRCA 109។ ចំណែកប្រភេទផ្សេងៗទៀតដូចជា PB310, PB314, IRCA109, KV4, PRIC100, RRIM600កំពុងស្ថិតក្នុងដំណាក់កាលពិសោធន៍។

## ២.៣ ផលិតកម្មកៅស៊ូ

ការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជាបានចាប់ផ្តើមឡើងពីឆ្នាំ១៩១០ ពេលដែលជនជាតិបារាំងម្នាក់ឈ្មោះ Bouillard បាននាំពូជកៅស៊ូចូលមក។ចំការទីមួយត្រូវបានបង្កើតឡើងនៅព្រៃនុប ខេត្តកំពត(បច្ចុប្បន្ននៅក្នុងខេត្តព្រះសីហនុ) លើផ្ទៃដីលាយខ្សាច់១៥០ហិចតា។ ដោយសារលក្ខខណ្ឌអាកាសធាតុមិនអំណោយផល និងដីខ្វះជីវជាតិ ធ្វើឲ្យទិន្នផលជ័រនៅមានកំរិតទាប គឺប្រហែល២០០គីឡូក្រាម/ហិចតា។ ទំហំនៃការអភិវឌ្ឍបានកើនឡើងកាន់តែច្បាស់ក្នុងកំឡុងដើមទស្សវត្ស១៩២០ដែលបានចាប់ផ្តើមអនុវត្តនូវការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនផ្សេងៗដែលគ្រប់គ្រងដោយវិនិយោគិនសាសន៍បារាំងដូចជា:

- Compagnie du Cambodge in Chup;
- SPRM (Société des Plantations de Mimot);
- CAMEKONG (Société des Caoutchoucs de Mekong in Prek Kak);
- SCKT (Societe des Caoutchoucs de Kompong Thom) in Chamcar Loeu and Chamcar Andong; and
- SKP (Société des Caoutchoucs de Kratie).

ទាំងផលិតផល ទាំងផលិតភាព បានកើនឡើងចាប់ពីពេលនោះមក ហើយបានឡើងដល់កំពូលនៅពាក់កណ្តាលទស្សវត្ត១៩៦០ ជាមួយនឹងផ្ទៃដីដាំដុះប្រហែល១៥០,០០០ហិចតា

និងទិន្នផលជិត១.៥តោន/ហិចតា [1]នេះគឺដោយសារតែការជួយជ្រោមជ្រែងរបស់វិនិយោគិនទាំងនេះ រួមផ្សំនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយជំរុញឲ្យមានម្ចាស់ចំការកៅស៊ូឯកជនក្នុងចំណោមប្រជាជនកម្ពុជា(**តារាង២**).

ក្នុងចន្លោះពេលឆ្នាំ១៩៧០ និង១៩៨០ ផលិតផលកៅស៊ូកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំងដោយសារ:

- ជំលោះរវាងវៀតណាម និងសហរដ្ឋអាមេរិច និង
- ការគ្រប់គ្រងអំណាចបន្តដោយខ្មែរក្រហម(១៩៧៥ – ១៩៧៩)។

ក្នុងកំឡុងពេលនោះ ចំការកៅស៊ូរាប់ពាន់ហិចតានៅតាមបណ្តោយព្រំដែនវៀតណាមខាងត្បូងបានទទួលរងធ្ងន់ធ្ងរពីការទំលាក់គ្រាប់បែក B-52 របស់អាមេរិចកាំង និងពីការបាញ់ថ្នាំគីមីAgent Orange ដើម្បីបញ្រ្ចុសស្លឹកកៅស៊ូ។ ការគ្រប់គ្រងអំណាចដោយពួកខ្មែរក្រហមបាននាំមកនូវការខូចវិចរិលយ៉ាងខ្លាំងចំពោះចំការកៅស៊ូ ដោយសារការមិនយកចិត្តទុកដាក់ថែទាំ និងទុកចោលអស់រយៈពេលយូរ។ ចាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ ចំការកៅស៊ូបានចាប់ផ្តើមរស់រានឡើងវិញ(**តារាង៣**)។

ការត្រលប់មកវិញនៃវិស័យនេះ គឺជាលទ្ធផលនៃជំនួយបច្ចេកទេសរបស់សហភាពសូវៀត និងប្រទេសអឺរ៉ុបមួយចំនួន។ នៅដើមទសវត្ស១៩៩០ ចំការកៅស៊ូត្រូវបានរៀបចំបានល្អជាងមុន ទៅជាចំការកៅស៊ូរដ្ឋចំនួន-៧ ឯកជន-២ និងចំការរបស់កម្មសិទ្ធករតូចៗមួយចំនួនទៀត។

សម្រាប់២ឆ្នាំចុងក្រោយ ២០០៨ និង២០០៩ ចំការកៅស៊ូបានកើនឡើងគួរឲ្យកត់សំគាល់។ ផ្ទៃដីដាំដុះនៅឆ្នាំ២០០៨ មាន១០៧,៩០០ហិចតា ដោយមានការកើនឡើង៣១%បើធៀបនឹងឆ្នាំ២០០៧។ ស្រដៀងគ្នានោះដែរផ្ទៃដីដាំដុះនៅឆ្នាំ២០០៩ មាន១២៧,៧២៣ហិចតា ដោយមានការកើនឡើង១៨%បើធៀបនឹងឆ្នាំ២០០៨(**តារាង៤**)។

---

[1] Hing Vuthea and Thun Vathana, December 2009, Agricultural Trade in the Greater Mekong sub-region, working Paper Series N$^0$ 43, CDRI.

តារាង ២:ផលិតផល និងផលិតភាពកៅស៊ូ(១៩២៨-១៩៦៦)

| ឆ្នាំ | ហិចតា | | | ផលិតផល/តោន | ទិន្នផល (kg/ha) |
|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ | ផ្ទៃដីមិនទាន់ចៀរ | ផ្ទៃដីកំពុងចៀរ | | |
| 1928 | 15.286 | 14.086 | 1.200 | 196 | 163 |
| 1929 | 18.542 | 15.747 | 1.800 | 340 | 189 |
| 1930 | 22.959 | 21.159 | 1.800 | 482 | 268 |
| 1931 | 25.618 | 21.118 | 4.500 | 698 | 155 |
| 1932 | 26.218 | 20.618 | 5.600 | 1.570 | 280 |
| 1933 | 26.218 | 18.518 | 7.700 | 2.265 | 294 |
| 1934 | 26.436 | 13.236 | 13.200 | 3.288 | 249 |
| 1935 | 26.441 | 5.867 | 20.579 | 6.496 | 316 |
| 1936 | 26.441 | 2.787 | 23.654 | 10.147 | 429 |
| 1937 | 26.469 | 2.019 | 24.450 | 13.715 | 561 |
| 1938 | 26.667 | 1.749 | 24.918 | 15.278 | 613 |
| 1939 | 28.005 | 2.804 | 25.201 | 17.327 | 687 |
| 1940 | 27.977 | 1.970 | 26.007 | 19.988 | 767 |
| 1941 | 28.085 | 2.278 | 25.807 | 20.821 | 807 |
| 1942 | 28.094 | 2.287 | 25.807 | 21.492 | 833 |
| 1943 | 28.264 | 2.757 | 25.807 | 21.616 | 847 |
| 1944 | 30.184 | 5.472 | 24.712 | 18.346 | 742 |
| 1945 | 29.922 | 6.235 | 23.687 | 4.552 | 192 |
| 1946 | 30.207 | 11.587 | 18.620 | 6.563 | 352 |
| 1947 | 30.240 | 10.514 | 19.726 | 13.212 | 170 |
| 1948 | 30.225 | 10.037 | 20.188 | 16.335 | 809 |
| 1949 | 30.281 | 10.061 | 20.220 | 15.616 | 772 |
| 1950 | 30.386 | 8.207 | 22.179 | 15.295 | 690 |
| 1951 | 30.397 | 7.103 | 23.294 | 15.631 | 671 |
| 1952 | 30.681 | 5.499 | 25.182 | 18.432 | 732 |
| 1953 | 30.721 | 4.181 | 26.540 | 22.338 | 843 |
| 1954 | 31.271 | 3.559 | 27.712 | 24.127 | 871 |
| 1955 | 31.536 | 2.548 | 28.988 | 27.848 | 961 |
| 1956 | 32.432 | 4.035 | 28.397 | 32.084 | 1.130 |
| 1957 | 34.136 | 5.734 | 28.402 | 31.684 | 1.115 |
| 1958 | 35.622 | 7.035 | 28.587 | 33.621 | 1.176 |
| 1959 | 36.898 | 8.309 | 28.589 | 34.468 | 1.205 |
| 1960 | 39.169 | 10.745 | 28.424 | 32.109 | 1.305 |
| 1961 | 41.543 | 12.789 | 28.754 | 39.980 | 1.390 |
| 1962 | 43.400 | 13.400 | 30.000 | 40.500 | 1.350 |
| 1963 | 45.143 | 15.226 | 29.917 | 40.755 | 1.362 |
| 1964 | 46.687 | 15.782 | 30.905 | 45.873 | 1.482 |
| 1965 | 47.726 | 15.108 | 32.618 | 48.916 | 1.499 |
| 1966 | 49.558 | 14.740 | 34.818 | 51.330 | 1.474 |

ប្រភព: MAFF, Undated, Rubber Plantation in Cambodia.

**តារាង ៣. ចំការកៅស៊ូកម្ពុជា ១៩៨០-២០០៩**

| ឆ្នាំ | ផ្ទៃដីដាំកៅស៊ូ សរុប (ហិ.) | ផ្ទៃដីកៅស៊ូ ចាស់ (ហិ.) | ផលិផល (តោន) | ទិន្នផល (គ.ក្រ/ហិ) | នាំចេញ (តោន) |
|---|---|---|---|---|---|
| 1980 | 5,000 | 5,000 | 1,300 | 260 | 1,454 |
| 1981 | 8,800 | 8,800 | 4,000 | 450 | 2,616 |
| 1982 | 11,800 | 11,800 | 7,000 | 590 | 8,000 |
| 1983 | 14,546 | 14,546 | 9,000 | 610 | 10,021 |
| 1984 | 19,506 | 19,506 | 13,388 | 680 | 13,307 |
| 1985 | 26,300 | 26,300 | 17,645 | 490 | 16,421 |
| 1986 | 35,779 | 35,779 | 24,497 | 680 | 23,280 |
| 1987 | 40,000 | 40,000 | 24,917 | 620 | 26,335 |
| 1988 | 41,500 | 41,500 | 31,380 | 750 | 29,958 |
| 1989 | 46,789 | 46,789 | 33,645 | 710 | 33,727 |
| 1990 | 51,160 | 51,122 | 34,700 | 680 | 25,563 |
| 1991 | 51,670 | 51,670 | 35,000 | 670 | 24,807 |
| 1992 | 58,835 | 50,709 | 28,364 | 550 | 26,645 |
| 1993 | 43,545 | 43,334 | 22,345 | 510 | 20,990 |
| 1994 | 42,817 | 42,576 | 30,585 | 710 | 30,742 |
| 1995 | 45,048 | 44,523 | 35,427 | 800 | 34,413 |
| 1996 | 45,538 | 44,400 | 43,891 | 990 | 41,607 |
| 1997 | 44,466 | 43,499 | 43,503 | 1,000 | 44,799 |
| 1998 | 42,625 | 41,464 | 41,398 | 1,000 | 39,966 |
| 1999 | 38,413 | 37,358 | 44,043 | 1,180 | 43,221 |
| 2000 | 53,722 | 42,698 | 42,007 | 980 | 40,066 |
| 2001 | 51,458 | 37,680 | 38,562 | 1,020 | 35,672 |
| 2002 | 55,482 | 36,773 | 32,384 | 880 | 36,774 |
| 2003 | 53,527 | 32,696 | 32,382 | 960 | 32,764 |
| 2004 | 54,209 | 31,590 | 33,770 | 1,060 | 33,558 |
| 2005 | 60,406 | 30,402 | 29,464 | 960 | 29,950 |
| 2006 | 69,994 | 32,390 | 32,077 | 990 | 31,184 |
| 2007 | 82,059 | 30,491 | 32,975 | 1,080 | 33,121 |
| 2008 | 108,510 | 34,313 | 37,050 | 1,080 | 36,000 |
| 2009 | 129,920 | 34,135 | 37,380 | 1,095 | 36,500 |

Source: General Directorate of Rubber/Rubber Development Dept. Update: 31.12. 2009

តារាង៤: ផលិតផល និងផលិតភាពតាមចំការ២០០៨ –២០០៩

| ចំការ | ផ្ទៃដី (ហិចតា) | | | | | | ផលិតផល(ត) | | ទិន្នផល(ត/ហ.) | |
|---|---|---|---|---|---|---|---|---|---|---|
| | ដីចៀរហើយ | | ដីមិនទាន់ចៀរ | | សរុប | | | | | |
| I. សិប្បកម្ម ចំការកៅស៊ូ | 2008 | 2009 | 2008 | 2009 | 2008 | 2009 | 2008 | 2009 | 2008 | 2009 |
| 1. ជប់ | 6,269 | 6,249 | 8,586 | 7,939 | 14,856 | 14,188 | 9,027 | 8,980 | 1.14 | 1.44 |
| 2. ពាមចេង | 2,001 | 2,160 | 2,314 | 1,570 | 4,315 | 3,780 | 2,153 | 1,915 | 1.08 | 0.89 |
| 3. ក្រែក | 1,363 | 1,414 | 2,588 | 3,040 | 3,951 | 4,454 | 966 | 1,736 | 0.71 | 1.23 |
| 4. មេមត់ | 1,903 | 2,181 | 3,000 | 2,600 | 4,903 | 4,782 | 1,213 | 1,590 | 0.64 | 0.73 |
| 5. ស្នួល | 1,004 | 883 | 1,870 | 1,996 | 2,874 | 2,878 | 1,065 | 639 | 1.06 | 0.72 |
| 6. ចំការអណ្តូង | 1,955 | 1,746 | 2,178 | 3,148 | 4,133 | 4,894 | 1,341 | 1,364 | 0.69 | 0.78 |
| 7. បឹងកេត | 1,300 | 1,075 | 2,500 | 2,078 | 3,800 | 3,103 | 650 | 994 | 0.50 | 0.97 |
| 8. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូ | 284 | 248 | 445 | 429 | 729 | 677 | 184 | 262 | 0.65 | 1.06 |
| 9. តាប៉ាស | 1,053 | 1,015 | 1,265 | 1,253 | 2,318 | 2,268 | 559 | 470 | 0.53 | 0.46 |
| 10.ឡាបានសៀក | 3,500 | 2,589 | 90 | 132 | 3,590 | 2,721 | 2,133 | 1,987 | 0.61 | 0.77 |
| 11. ដីសម្បទាន (23 ក្រុមហ៊ុន) | 0 | 0 | 8,205 | 23,349 | 8,205 | 23,349 | 0 | 0 | 0 | 0 |
| [redacted] | | | | | | | | | | |
| II. កម្មសិទ្ធករខ្នាតតូច | 13,057 | 14,625 | 41,190 | 46,055 | 54,227 | 60,680 | 12,385 | 17,444 | 0.95 | 1.19 |
| [redacted] | | | | | | | | | | |

*យោងតាម MAFF Annual Report 2009-2010, 2010-2011.

តួលេខនេះមានភាពខុសគ្នាបន្តិចបន្តួចពីតួលេខដែលផ្តល់ឲ្យដោយអគ្គលេខាធិការដ្ឋានចំការកៅស៊ូនៅតារាង៣។

ទិន្នផលក្នុង១ហិចតាមានកំរិតទាប គឺ១.០២តោន/ហិចតា និង១.១៩តោន/ហិចតា សម្រាប់ចំការឧស្សាហកម្មធុនធំ និងកម្មសិទ្ធករខ្នាតតូចរៀងគ្នា។ ទិន្នផលជាមធ្យមគឺ

១.០៩តោន/ហិចតា បើធៀបនឹងប្រទេសឥណ្ឌា១.៨តោន/ហិចតា ម៉ាឡេស៊ី១.៦តោ/ហិចតា ថៃ១.៧តោន/ហិចតា វៀតណាម១.៨តោន/ហិចតា និងប្រទេសចិន១.២តោន/ហិចតា។

## ២.៤ ការប្រមូល និងពាណិជ្ជកម្មកៅស៊ូ

អ្នកប្រមូលទិញ និងពាណិជ្ជករកៅស៊ូ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញលំហូរកៅស៊ូធម្មជាតិពីកសិដ្ឋានទៅដល់រោងចក្រកែច្នៃកៅស៊ូ។ កសិករនៅក្បែររោងចក្រ លក់ផលិតផលរបស់ពួកគាត់ក្នុងទម្រង់ជាជ័រនៅ(ទើបតែប្រមូលបានពីដើម (latex))ដល់រោងចក្រតែម្តង ចំណែកឯអ្នកនៅឆ្ងាយពីរោងចក្របានបំលែងជ័រនៅទៅជាទម្រង់ខាប់រឹង(coagulum) មុននឹងលក់។ ដើម្បីធ្វើជ័រនៅឲ្យរឹងកសិករគ្រាន់តែបង្ហូរជ័រនោះទៅក្នុងរណ្តៅមួយ ហើយទុកវាពីរ ឬបីថ្ងៃមុននឹងអ្នកទិញមកដល់។

ក្នុងចង្វាក់ពាណិជ្ជកម្ម អ្នកប្រមូលទិញខ្នាតតូចជាទូទៅលក់កៅស៊ូឲ្យសាខារបស់ភ្នាក់ងារមិនផ្លូវការនៃអ្នកកែច្នៃដែលដើរតួដូចជាអ្នកប្រមូលឯកជនមិនផ្លូវការ។ កម្មសិទ្ធករខាតតូចបានចុះកុងត្រាជាមួយអ្នកប្រមូលទាំងនេះ។ ប៉ុន្តែ អ្នកប្រមូលទិញច្រើនតែខាតប្រយោជន៍ដោយសារកម្មសិទ្ធករខាតតូចមិនគោរពកុងត្រា នៅពេលតំលៃទីផ្សារកើនក្នុងចន្លោះពី៥ទៅ១០% ខ្ពស់ជាងតំលៃក្នុងកុងត្រា។ កម្មសិទ្ធករខ្នាតតូចបច្ចុប្បន្ន មានជំរើសច្រើនជាងមុនក្នុងការលក់ជ័រនៅរបស់គាត់។ នេះជាលទ្ធផលនៃសេដ្ឋកិច្ចទីផ្សារសេរីដែលអនុញ្ញាតិឲ្យពាណិជ្ជករ និងសហគ្រិនទិញផលិតផលរបស់ពួកគេ។ ខាងក្រោមនេះជារូបដែលពន្យល់ពីខ្សែចង្វាក់ម៉ាយីទិញនៃផលិតកម្មកៅស៊ូ។

**រូបទី១: ខ្សែចង្វាក់ផលិតកម្មកៅស៊ូ**




ប្រភព: CDRI Working Paper Series N° 43, December 2009

អ្នកលក់ដុំទិញជ័រនៅពីកម្មសិទ្ធករខ្នាតតូចសម្រាប់លក់ ឬនាំទៅឲ្យរោងចក្រដើម្បីកែច្នៃ និងនាំចេញ។ អ្នកប្រមូលទិញខ្នាតតូចទិញជ័រនៅពីកសិដ្ឋាន ហើយលក់វាទៅឲ្យអ្នកលក់ដុំ ឬរោងចក្រក្នុងតំបន់របស់គាត់។ ប៉ុន្តែអ្នកប្រមូលទិញមួយចំនួនទិញកៅស៊ូដើម្បីលក់ផ្ទាល់ឲ្យវៀតណាមតែម្តង ពួកគាត់ដឹកជញ្ជូនកៅស៊ូតាមម៉ូតូ ដែលអាចផ្ទុកបានរហូតដល់៣០០គីឡូក្រាម។ អ្នកលក់ដុំម្នាក់អាចទិញក្នុងចន្លោះពី១០ទៅ២០តោនក្នុង១ថ្ងៃ ប៉ុន្តែទំហំនេះអាចត្រូវបានកាត់បន្ថយដល់១០តោន នៅពេលដែលអ្នកប្រមូលទិញខ្នាតតូចមានសកម្មភាពយ៉ាងខ្លាំងក្នុងការលក់ផលិតផលរបស់គាត់ផ្ទាល់ទៅវៀតណាមតែម្តងទោះជាមិនស្របច្បាប់ក៏ដោយ។

## ២.៥ ដំណើរការកែច្នៃកៅស៊ូ

ចំការកៅស៊ូរដ្ឋទាំង៧ដែលបានធ្វើឯកជនភាវូបនីយកម្មពីដើមឆ្នាំ២០០៩ មានរោងចក្រកែច្នៃរបស់ខ្លួន។ ទំហំផលិតផលមធ្យមនៃរោងចក្រទាំង៧ មានក្នុងចន្លោះពី១ទៅ២តោនក្នុង១ម៉ោង។ ការកើនឡើងគួរឲ្យកត់សំគាល់នូវចំនួនកម្មសិទ្ធករខ្នាតតូច និងម្ចាស់ចំការកៅស៊ូឯកជននៅឆ្នាំ២០០៨ និង២០០៩ ការកើនឡើងទ្វេដងនៃការប្រើប្រាស់កៅស៊ូនៅលើពិភពលោក អាចលើកទឹកចិត្តវិស័យឯកជនក្នុងការបង្កើតរោងចក្រកែច្នៃកៅស៊ូដែលបំលែងពីជ័រកៅស៊ូទៅទៅជាដុំកៅស៊ូស្ងួតសម្រាប់នាំចេញ។

## ២.៦ ការនាំចេញកៅស៊ូ(តារាង៥)

ព្រះរាជាណាចក្រកម្ពុជាបាននាំចេញផលិតផលកសិកម្មទៅប្រទេសថៃ និងវៀតណាមក្នុងបរិមាណមិនអាចកត់ត្រាបាន ក្នុងនោះការនាំចេញកៅស៊ូក៏ដូចគ្នាដែរ។ ស្ថិតិនៃការនាំចេញកៅស៊ូមានផ្សេងៗគ្នាពីប្រភពមួយទៅប្រភពមួយ។ ក្នុងន័យនេះ ស្ថិតិទាំងនោះមិនអាចត្រូវបានទុកចិត្តទាំងស្រុងទេ។ ទោះបីជាភាពខុសគ្នារវាងតួលេខកត់ត្រា និងមិនកត់ត្រា ត្រូវបានកាត់បន្ថយនៅឆ្នាំក្រោយៗនេះក៏ដោយ ក៏វានៅតែខ្ពស់ដដែល។ យោងតាមឯកសារមួយចំនួន បច្ចុប្បន្ននេះ តួលេខកៅស៊ូនាំចេញដែលមិនអាចកត់ត្រាបានមានជិតស្មើតួលេខដែលកត់ត្រាបាន។

អគ្គនាយកដ្ឋានចំការកៅស៊ូបានបង្ហាញថានៅឆ្នាំ២០០៧ ការនាំចេញកៅស៊ូមានសរុប ៣៣,១២១តោន(តារាង៣) និងបានទទួលប្រាក់ចំណូលចំនួន៦០,៨៨២,៨០៨ដុល្លារអាមេរិក គឺខុសគ្នាខ្ទង់៨៥%ពីតំលៃនាំចេញកៅស៊ូដែលផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ។ ការនាំចេញកៅស៊ូត្រូវជាប់ពន្ធនាំចេញ១០%ពេលតំលៃនាំចេញខ្ពស់ជាង

តារាង៥: បរិមាណ និងតំលៃនៃការនាំកៅស៊ូចេញរបស់ព្រះរាជាណាចក្រកម្ពុជា

| ប្រភេទ | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|
| បរិមាណនាំចេញ(តោន) | 37,048 | 33,228 | 28,289 | 25,427 | 24,815 | 14,467 |
| តំលៃនាំចេញ(លានដុល្លារអាមេរិច) | 35.1 | 38.3 | 36.7 | 41.5 | 41.6 | 36.09 |
| តំលៃក្នុង១តោន(ដុល្លារអាមេរិច) | 947.42 | 1,152.64 | 1,297.32 | 1,632.15 | 1,676.41 | 2,494.64 |
| ការនាំចេញសរុប(លានដុល្លារអាមេរិច) | 1,708.08 | 2,108.15 | 2,352.75 | 2,799.95 | 3,098.74 | 3,097.79 |
| **ភាគរយធៀបការនាំចេញសរុប (%)** | 2.10 | 1.80 | 1.60 | 1.50 | 1.30 | 1.20 |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ, 2009

៨៩០ដុល្លារ/តោន ដែល មានសុពលភាពដល់ចុងឆ្នាំ២០០៨។ មិនមានការពន្យល់ច្បាស់លាស់អំពីភាពខុសគ្នានៃតួលេខទាំងនេះទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការគេចពន្ធ អាចជាហេតុមួយដែរ។

ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចពិភពលោកដែលបានធ្វើឲ្យតំលៃកៅស៊ូថយចុះចាប់ពីឆមាសចុងក្រោយឆ្នាំ២០០៨មក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសលេខ ៦៧៩៨ SHV ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ស្តីពីការបង្កើតតារាងពន្ធថ្មីលើការនាំចេញកៅស៊ូ។ អត្រាពន្ធដែលមានសុពលភាពចាប់ពីខែមករា ឆ្នាំ២០០៩ មានដូចជា:

ក.០.០ដុល្លារអាមេរិក/តោន ប្រសិនបើតំលៃកៅស៊ូទាបជាង៧០០ដុល្លារអាមេរិក/តោន

ខ. ១០.០ដុល្លារអាមេរិក/តោន ប្រសិនបើតំលៃក្នុងចន្លោះពី៧០០ដុល្លារអាមេរិក/តោន ទៅ១,០០០ដុល្លារអាមេរិក/តោន

គ. ៣០.០ដុល្លារអាមេរិក/តោន ប្រសិនបើតំលៃក្នុងចន្លោះពី១,០០០ដុល្លារអាមេរិក /តោនទៅ១,៥០០ដុល្លារអាមេរិក/តោន

ឃ. ៥០.០ដុល្លារអាមេរិក/តោន ប្រសិនបើតំលៃខ្ពស់ជាងទៅ១,០០០ដុល្លារ អាមេរិក/តោនឡើងទៅ។

លើសពីនេះអ្នកនាំចេញកៅស៊ូត្រូវបង់ពន្ធលើតំលៃបន្ថែម(VAT) ១០%លើតំលៃកៅស៊ូធម្មជាតិដែលលក់ក្នុងប្រទេស ។ នៅពេលដែល ប្រតិបត្តិការនាំចេញត្រូវបានបំពេញរួចហើយ អ្នកនាំចេញអាចសុំដកពន្ធលើតំលៃបន្ថែមមកវិញ។ រហូតមកដល់បច្ចុប្បន្ន កៅស៊ូដែលផលិត

នៅកម្ពុជា ទុកសម្រាប់តែនាំចេញប៉ុណ្ណោះ ដោយសារការខ្វះសមត្ថភាព និងការ វិនិយោគក្នុងការកែច្នៃ។ មានតែផលិតផលកៅស៊ូស្ងួតពាក់កណ្ដាលកែច្នៃ(មិនមែនជ័រកៅស៊ូឆៅ)ត្រូវបានអនុញ្ញាត្តិឲ្យនាំចេញ ហើយនេះធ្វើឲ្យកម្មសិទ្ធករខ្នាតតូចមានជំរើសតិចតួចណាស់ក្នុងការនាំចេញ ដូច្នេះពួកគាត់ត្រូវតែលក់ជ័រកៅស៊ូឆៅដែលប្រមូលបានឲ្យទៅក្រុមហ៊ុនឯកជនធំៗសម្រាប់កែច្នៃ និងនាំចេញ។ កម្ពុជាផលិត និងនាំចេញកៅស៊ូភាគច្រើនក្នុងប្រភេទCSR5 និង CSR5L ដែលមានចំនួនជិត៨០%នៃបរិមាណនាំចេញទាំងអស់នៅឆ្នាំ២០០៥(EIC, 2007).។ ទោះជាយ៉ាងណាក្តី បមាណភាគនៃប្រភេទទាំងពីរមានតែ៥%នៃតម្រូវការលើសកល លោកទាំងមូលតែប៉ុណ្ណោះ។

ការនាំចេញកៅស៊ូរបស់កម្ពុជាមានកំរិតទៅតែកន្លែងមួយចំនួនប៉ុណ្ណោះ ជាពិសេសទៅប្រទេសវៀតណាម ម៉ាឡេស៊ី ចិន សាំងកាពួរ និងកូរ៉េខាងត្បូង។ វៀតណាមជាកន្លែងនាំមុខដោយសារមូលហេតុដូចខាងក្រោម:

- ចំការកៅស៊ូកម្ពុជាភាគច្រើនស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលជួយជាមាត់ច្រកចេញចូលយ៉ាងងាយ ថ្លៃរត់ការទាប និងចំណាយលើការដឹកជញ្ជូនទាប
- ពាណិជ្ជករវៀតណាមទទួលទិញលើជ័រកៅស៊ូឆៅដែលមានគុណភាពទាប
- មិនត្រូវការវិញ្ញាបណ្ណប័ត្របញ្ជាក់គុណភាព
- ការទូទាត់មានភាពងាយស្រួល ជាទូទៅជាសាច់ប្រាក់។ ប្រសិនបើផលិតផលត្រូវបានលក់ទៅឲ្យប្រទេសផ្សេង ការទូទាត់ត្រូវឆ្លងកាត់បែបបទត្រឹមត្រូវតាមធនាគារដែលទៀមទារការបង់កំរៃបន្ថែម និងរយៈពេលយូរមុននឹងអ្នកលក់អាចទទួលការបង់ថ្លៃបាន។
- ពិសេសជាងនេះទៅទៀត បើទោះបីជាតំលៃនៅទីផ្សារវៀតណាមទាបជាងនៅប្រទេសផ្សេងៗក៏ដោយ ផលិតករក្នុងស្រុកមានទំនោរលក់ឲ្យពាណិជ្ជករវៀតណាម ពិព្រោះភាពខុសគ្នានៃតំលៃនៅទីផ្សារទាំងពីរជាការធម្មតា គឺទាប

ជាងការចំណាយលើការដឹកជញ្ជូន និងថ្លៃរត់ការយកទៅដល់កន្លែងលក់នៅកំពង់ផែក្រុងព្រះសីហនុ។

តារាង៦បង្ហាញថាទីផ្សារវៀតណាមនៅតែរក្សារជាកន្លែងនាំចេញនាំមុខគេសម្រាប់កៅស៊ូធម្មជាតិរបស់កម្ពុជា។ប្រទេសម៉ាឡេស៊ីជាកន្លែងទី២ ក៏ប៉ុន្តែមានកំណើនកើនឡើងខ្លាំងពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧។ អ្វីដែលគួរឲ្យងឿងឆ្ងល់នោះ គឺព្រះរាជាណាចក្រកម្ពុជាក៏បាននាំចេញកៅស៊ូធម្មជាតិទៅទីផ្សារឆ្ងាយដែរ ដូចជាសហរដ្ឋអាមេរិក និងសហគមន៍អឺរុប។ ទាក់ទងនឹងសក្តានុពលទីផ្សារ កម្ពុជាមិនត្រូវបានកំណត់ព្រំដែនទេ ហើយជាមួយនឹងការទទួលស្គាល់ជាសមាជិកភាពក្នុងសហគមន៍កៅស៊ូអន្តរជាតិ(IRA)នៅខែមិនា ឆ្នាំ២០០៩ កម្ពុជាទទួលបានលទ្ធភាពទៅលក់នៅទីផ្សារផ្សេងៗទៀតដូចជាប្រទេសថៃ និងចិនជាដើម។

**តារាង៦: ការនាំចេញកៅស៊ូធម្មជាតិមិនទាន់កែច្នៃ (ពាន់ដុល្លារអាមេរិក)**

| ប្រទេស | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|
| វៀតណាម | - | 28,526 | 41,693 | 61,463 | 63,401 | 73,783 | - |
| ម៉ាឡេស៊ី | 10,017 | 10,031 | 2,715 | 2,481 | 3,940 | 7,509 | 15,826 |
| ចិន | 5,706 | 7,486 | 7,684 | 2,531 | 3,131 | 8,691 | 11,014 |
| សហរដ្ឋអាមេរិក | 1,184 | 972 | 1,100 | 2,348 | 1,156 | 2,872 | 1,659 |
| អេស្បាញ | 2,311 | 1,740 | 1,020 | 1,349 | 360 | 421 | 528 |
| តៃវ៉ាន់ | 182 | 239 | 209 | 423 | 84 | 421 | 137 |
| កូរ៉េខាងត្បូង | 1,257 | 980 | 703 | 668 | 637 | 167 | 42 |
| អ៊ីតាលី | 635 | 615 | 83 | 179 | - | - | - |
| ហ្វីលីពីន | 68 | - | - | 61 | 68 | - | - |
| សាំងហ្គាពូរ | 6,630 | 873 | 873 | 413 | - | - | - |
| ថៃ | - | - | - | - | - | - | - |

ប្រភព: Saing Chan Hang, ARTNet, paper series N° 1, July 2009

ក្នុងនាមជាសមាជិកសហគមន៍កៅស៊ូអន្តរជាតិ(IRA) កម្ពុជាអាចទាញយកផលចំណេញ បានដូចជា:

- វិញ្ញាបណ្ណប័ត្របញ្ជាក់គុណភាពកម្ពុជាត្រូវបានទទួលស្គាល់លើទីផ្សារអន្តរជាតិ
- កម្ពុជាត្រូវបំពេញកាតព្វកិច្ចមួយចំនួនឲ្យបានត្រឹមត្រូវតាមការទាមទាររបស់IRA ដូច្នេះជួយកម្ពុជាឲ្យពង្រីកសមត្ថភាពផលិតបច្ចុប្បន្នរបស់ខ្លួន កែលំអរទិន្នផលកៅស៊ូតាមរយៈការអនុវត្តនូវបច្ចេកវិទ្យាទំនើប និងគាំទ្រដល់ការនាំចេញផលិតផលឧស្សាហកម្ម និងការបង្កើនល្បឿននៃកំណើន។

## ២.៧ ការចំណាយ និងផលចំណេញ

យោងតាមការស្ទង់មតិរបស់ CDRI នៅខែឧសភា ឆ្នាំ២០០៧៖

- កសិករអាចលក់ជ័រកៅស៊ូនៅក្នុងរង្វង់១,៧៥០ដុល្លារ/តោននៅនឹងកន្លែង
- ឈ្មួញកណ្តាល ឬអ្នកលក់ដុំដឹកជញ្ជូនកៅស៊ូស្ងួត និងរក្សាវាក្នុងតំលៃជិត១២៥ ដុល្លារ/តោន
- តំលៃកែច្នៃកៅស៊ូស្ងួតរង្វង់១០០ដុល្លារ/តោន
- ថ្លៃដឹកជញ្ជូនទៅវៀតណាមតាមផ្លូវលំមានប្រហែលពី៣ដុល្លារទៅ៤ដុល្លារ/តោន /១០គីឡូម៉ែត្រ
- ពន្ធនាំចេញកៅស៊ូមាន១០%នៃតំលៃផលិតផលនាំចេញ
- ថ្លៃក្រោមតុមានប្រហែល៥%នៃតំលៃផលិតផលនាំចេញ
- ថ្លៃលក់គឺប្រហែល២,៣៣០.០០ដុល្លារ/តោននៅពេលស្ទង់មតិ។

## ៣. បញ្ហាប្រឈម និងឧបសគ្គ

ឯកសារសំខាន់ៗជាច្រើន ក៏ដូចជាព័តមានបានពីការស្ទង់មតិបានបញ្ជាក់ពីបញ្ហារួមមួយចំនួនទាក់ទងនឹងផ្នែកផ្គត់ផ្គង់កៅស៊ូក្នុងស្រុក។ បញ្ហាទាំងនោះរួមមាន:

ក. <u>ការប្រកួតប្រជែងថ្លៃដើមមិនមានប្រសិទ្ធភាព:</u> សមមាត្រថ្លៃនាំកៅស៊ូចេញបង្កើតឡើងដោយថ្លៃក្រោមតុ ពន្ធលើថ្លៃបន្ថែម និងពន្ធនាំចេញ។ ពន្ធលើថ្លៃបន្ថែមនៃការលក់កៅស៊ូធម្មជាតិនៅវៀតណាមមានតែ៥% ហើយគ្មានពន្ធនាំចេញទេ។ នៅប្រទេសថៃពន្ធលើការនាំចេញភាគច្រើនមានកំរិតទាប គឺពី២០ ទៅ៣៣ដុល្លារអាមេរិក/តោន។

ខ. <u>ការគាំទ្រផ្នែកពាណិជ្ជកម្ម:</u> ទាក់ទងក្នុងផ្នែកនេះ កម្ពុជានៅមានលក្ខណៈអន់ថយជាងប្រទេសជិតខាងភាគច្រើន លើកលែងតែសាធារណៈរដ្ឋប្រជាមានិតឡាវ។ កម្ពុជាបានបង្ហាញនូវភាពមិនល្អទាក់ទងនឹងចំនួនឯកសារនៃការអនុញ្ញាតិឲ្យនាំចេញ(**តារាង៧**)។

តារាង៧: ការប្រៀបធៀបចំណាយនៃការនាំចេញកៅស៊ូក្នុងតំបន់

| ប្រភេទ | កម្ពុជា | ឡាវ | វៀតណាម | ឥណ្ឌូនេស៊ី | ម៉ាឡេស៊ី | ថៃ |
|---|---|---|---|---|---|---|
| ចំនួនឯកសារនាំចេញ | 11 | 9 | 6 | 5 | 7 | 4 |
| រយៈពេលនាំចេញ(ថ្ងៃ) | 22 | 50 | 24 | 21 | 18 | 14 |
| ចំណាយលើការនាំចេញ (US$/container) | 732 | 1,860 | 734 | 704 | 450 | 625 |
| លំដាប់នៃភាពងាយស្រួលពាណិជ្ជកម្ម(ក្នុងចំណោម១៧៨) | 122 | 165 | 67 | 37 | 29 | 10 |
| ប្រសិទ្ធភាពការងារគយ* | 2.19 | 2.08 | 2.89 | 2.73 | 3.36 | 3.03 |
| គុណភាពដឹកជញ្ជូន* | 2.3 | 2 | 2.5 | 2.83 | 3.33 | 3.16 |
| នីតិវិធីការនាំចេញ* | 2.47 | 2.29 | 2.8 | 2.9 | 3.4 | 3.31 |

ប្រភព: World Bank, "Doing Business 2009"and World Trade Indicators, 2008

* ពិន្ទុខ្ពស់បង្ហាញពីការកែលំអរគុណភាព និងប្រសិទ្ធភាព(ទិន្នន័យឆ្នាំ២០០៧)

**គ. ខ្សែចង្វាក់ម៉ាយេទិញ និងការចំណាយលើការនាំចេញ:** បើទោះបីជាកសិករមានជំរើសច្រើនក្នុងការលក់ជ័រកៅស៊ូនៅរបស់គាត់ក៏ដោយ ពួកគាត់គ្រាន់តែជាអ្នកទទួលថ្លៃតែប៉ុណ្ណោះ។ តំលៃនៅកសិដ្ឋានតែងតែកំណត់ដោយអ្នកប្រមូលទិញ និងពួកពាណិជ្ជករ។ លើសពីនេះទៀតថ្លៃនៅទីផ្សារអន្តរជាតិ គឺជាថ្លៃដែលមិនស្ថិតស្ថេរ និងគ្មានការធានាសុវត្ថិភាពថ្លៃទេ។

**ឃ. ផលិតភាពទាប:** ទិន្នផលកៅស៊ូមធ្យមនៅកម្ពុជា គឺនៅទាបបើធៀបនឹងប្រទេសផលិតកៅស៊ូភាគច្រើននៅក្នុងតំបន់ ដោយដោយហេតុថាដើមកៅស៊ូមានអាយុកាលចាស់ ការប្រើប្រាស់គ្រាប់ពូជដែលផ្តល់ផលទាប និងការលួចជ័រដោយអ្នកចៀរជ័រ។ ជ័រដែលគេលួចមិនបានកត់ត្រាចូលក្នុងតួលេខផលិតផលទេ។ ការលួចនេះធ្លាប់កើតមានយ៉ាងខ្លាំងនៅពេលដែលចំការកៅស៊ូធ្លាប់គ្រប់គ្រងដោយរដ្ឋ ប៉ុន្តែឥឡូវនេះត្រូវបានកាត់បន្ថយជាច្រើន។

ង. <u>ជ័រកៅស៊ូនៅមានគុណភាពទាប:</u> គុណភាពរបស់ជ័រកៅស៊ូប្រែប្រួល ដោយសារជ័រទាំងនោះប្រមូលបានពីកម្មសិទ្ធករខ្នាតតូច ជាពិសេសមានគុណភាពទាប និងមានលក្ខណៈលាយឡំគ្នា។

ច. <u>ការប្រើប្រាស់បច្ចេកវិទ្យានៅមានកំរិត:</u> បរិមាណរោងចក្រពាក់កណ្តាលកែច្នៃ(ផលិតកៅស៊ូដុំ) មិនទាន់មានប្រសិទ្ធភាព ហើយមិនទាន់មានរោងសិប្បកម្មដែលប្រមូលទិញវត្ថុធាតុដើមយកទៅកែច្នៃនៅឡើយ ដោយសារមធ្យោបាយហិរញ្ញប្បទានមិនមានគ្រប់គ្រាន់ និងបច្ចេកទេសនៅមានកំរិត។

ឆ. <u>ការយល់ដឹងអំពីទីផ្សារបរទេស និងបញ្ហាទាក់ទងនឹងពាណិជ្ជកម្មអន្តរជាតិនៅមានកំរិត:</u> ការគ្រប់គ្រងការលក់នៅមិនទាន់មានប្រសិទ្ធភាពឡើយ ក្រុមហ៊ុនតែងតែរងចាំអតិថិជនមកទាក់ទងជាមួយជាជាងស្វែងរកយ៉ាងសកម្មនូវសក្តានុពលថ្មី។ អាកប្បកិរិយាធូររលុងហើយមិនសកម្មបែបនេះ អាចធ្វើឲ្យខាតផលប្រយោជន៍ដល់អ្នកដាំ(ធំ ឬតូចក្តី)កម្ពុជានៅពេលអនាគត។ គេបានទោះទាយថានៅឆ្នាំ២០១៥ នៅពេលផលិតផលកៅស៊ូវៀតណាមអាចកើនដល់ចំណុចកំពូល វៀតណាមអាចមិនត្រូវការទិញកៅស៊ូស្ងួតពីកម្ពុជាទៀតទេ ឬក៏អាចទិញខ្លះក្នុងតំលៃទាបបំផុតដើម្បីនាំចេញបន្តទៅប្រទេសដទៃទៀត។ ផលិតករកៅស៊ូកម្ពុជាគួរចាប់ផ្តើមគិតពីពេលនេះទៅ ថាតើត្រូវពង្រីកទីផ្សាររបស់ខ្លួនទៅទីណា និងតើត្រូវអភិវឌ្ឍឧស្សាហកម្មដែលផ្តល់តំលៃបន្ថែមខ្ពស់ដូចជាឧស្សាហកម្មផលិតកង់ឡាន និងកង់ម៉ូតូ និងកង់ធម្មតា។

ជ. <u>សហគមន៍កៅស៊ូមិនសូវសកម្ម:</u> បច្ចុប្បន្ននៅកម្ពុជា មានសហគមន៍អភិវឌ្ឍកៅស៊ូតែមួយដែលមានសមាជិកភាពរាប់បញ្ចូលគ្រប់គ្នាទាំងអស់ អ្នកដែលពាក់ពន្ធនឹងការដាំ ការធ្វើពាណិជ្ជកម្ម ការកែច្នៃ ការនាំចេញកៅស៊ូ ព្រមទាំងមានបួនសហគមន៍របស់កម្មសិទ្ធករខ្នាតតូចប៉ុណ្ណោះ។ សហគមន៍ទាំងនេះមិនបានបង្ហាញពីសកម្មភាពរបស់ខ្លួនឲ្យបានល្អនោះទេ ហើយសមាជិករបស់សហគមន៍ទាំងនេះមិនបានទទួលផលចំណេញអ្វីដែរពីជំនួយបច្ចេកទេសនៃគំរោងដែលដឹកនាំដោយអគ្គនាយកដ្ឋានចំការកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ។

## ៤. សក្តានុពលភាព

ជាក់ស្តែងណាស់ ចំការកៅស៊ូនៅព្រះរាជាណាចក្រកម្ពុជាកំពុងប្រឈមនឹងបញ្ហាទូទៅមួយចំនួន ប៉ុន្តែសម្រាប់វិស័យនេះក៏ឃើញមានសក្តានុពលមួយចំនួនដូចខាងក្រោម។

ក. មូលដ្ឋានដីអាចពង្រីកបាន។ រហូតមកដល់ពេលនេះ មានតែផ្ទៃដីជាង១២០,០០០ហិចតាប៉ុណ្ណោះត្រូវបានដាំដុះ នៅពេលដែលតារាង១បានបង្ហាញថាសក្តានុពលដីក្រហមលាតសន្ធឹងនៅកម្ពុជាអាចដល់៧១៦,០០០ហិចតា។

ខ. ទិន្នផលក្នុងមួយហិចតាអាចបង្កើនបានដូចភស្តុតាងដែលបង្ហាញដោយប្រវិត្តតួលេខនៅតារាង២។ ទិន្នផលបានកើនឡើងជាលំដាប់ក្នុងចន្លោះពីឆ្នាំ១៩៥៦ និង១៩៦៦ គឺពី ១.១តោន/ហិចតា ទៅ១.៥តោន/ហិចតា។ ដូចគ្នានេះដែរតារាង៣បានបង្ហាញថា ទិន្នផលបានងាកទៅរកជាង១តោន/ហិចតាក្នុងរយៈពេលបីឆ្នាំចុងក្រោយគិតពីឆ្នាំ២០០៧មក បន្ទាប់ពីការឆ្លងកាត់អស់រយៈដ៏វែងនៃការធ្លាក់ចុះដែលបង្កើតឡើងដោយសង្គ្រាម។

គ. ការទទួលស្គាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(CRRI)បច្ចុប្បន្នដោយសហគមន៍ស្រាវជ្រាវអន្តរជាតិ ធ្វើឲ្យមានភាពល្អដល់ការអភិវឌ្ឍចំការកៅស៊ូក្នុងទិសដៅច្រើនដូចជា:

- ការស្រាវជ្រាវរកក្លូនថ្មីដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវទិន្នផល គុណភាព និងលទ្ធភាពប្រឆាំងនឹងជំងឺ និងការប្រែប្រួលបរិស្ថាន
- ការពង្រឹងទីផ្សារអន្តរជាតិតាមរយៈការទទួលស្គាល់ជាអន្តរជាតិនូវវិញ្ញាបណ្ណបត្របញ្ជាក់ពីគុណភាពដែលផ្តល់ដោយ(CRRI)
- ការបង្កើនសមត្ថភាពអ្នកស្រាវជ្រាវ។

ឃ. តម្រូវការ និងការប្រើប្រាស់កៅស៊ូទូទាំងពិភពលោកនៅតែមានការវិវត្តជាវិជ្ជមានទៀតនៅថ្ងៃក្រោយ ជាពិសេសជាមួយនឹងកំណើនសេដ្ឋកិច្ចនៅប្រទេសចិន និងឥណ្ឌា ថ្វីត្បិតតែមានការគំរាមកំហែងនៃការជំនួសកៅស៊ូធម្មជាតិដោយកៅស៊ូសិប្បនិមិត្តអាចត្រូវបានកើនឡើងក៏ដោយ។

## ៥. ការគំរាមកំហែង

ការគំរាមកំហែងធំៗចំពោះចំការកៅស៊ូ និងឧស្សាហកម្មកៅស៊ូមានដូចជា:

ក. ចក្ខុវិស័យដ៏តូចចង្អៀតរបស់ម្ចាស់ចំការកៅស៊ូដែលពេញចិត្តតែនឹងការផលិតកៅស៊ូស្ងួតដើម្បីនាំចេញ ហើយមិនចង់កែច្នៃបន្តនូវផលិតផលនេះឲ្យបានជាផលិតផលសម្រាប់ការប្រើប្រាស់ចុងក្រោយ។

ខ. ការបំពេញតួនាទីមិនមានប្រសិទ្ធភាពរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ ដោយសារខ្វះហិរញ្ញវត្ថុ។

គ. ខ្វះការប្តេជ្ញាចិត្តពីអជ្ញាធរដែលទទួលខុសត្រូវក្នុងការជំរុញការអភិវឌ្ឍឧស្សាហកម្មកៅស៊ូដែលផ្តល់តំលៃបន្ថែមខ្ពស់។

## ៦. អនុសាសន៍

បន្ទាប់ពីបញ្ចប់ការវាយតំលៃអំពីចំការកៅស៊ូ និងវិស័យពាក់ព័ន្ធផ្សេងៗ អនុសាសន៍មួយចំនួនដូចខាងក្រោមត្រូវបានលើកឡើងដើម្បីលើកកំពស់កៅស៊ូឲ្យទៅជាទំនិញសេដ្ឋកិច្ចដែលនឹងពញ្ញាក់និង ជួយជំរុញដល់កំណើនសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រៈ

ក. រាជរដ្ឋាភិបាលនៃកម្ពុជាគួរផ្តល់ការគាំទ្រឲ្យបានខ្លាំងក្លាផ្នែកហិរញ្ញប្បទានដល់អគ្គនាយកដ្ឋានចំការកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ។ ប្រសិនបើអាច មួយផ្នែកនៃពន្ធនាំចេញអាចដកចេញយកមកប្រើក្នុងវិស័យស្រាវជ្រាវ និងអភិវឌ្ឍឧស្សាហកម្មកៅស៊ូ។ ជាមួយនឹងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ អគ្គនាយកដ្ឋានចំការកៅស៊ូអាចពង្រឹងសហគមន៍កៅស៊ូដែលមានស្រាប់ឲ្យក្លាយទៅជាវិទ្យាស្ថានឯករាជ្យ និងម្ចាស់ការ។ តាមរយៈការពង្រីកដែលមានលក្ខណៈប្រពលវប្បកម្ម និងយ៉ាងមានប្រសិទ្ធភាព និងតាមរយៈកម្មវិធីបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ សហគមន៍ទាំងនេះអាចយល់ដឹងនូវបញ្ហាដែលទាក់ទងនឹងការដាំការផលិត និងគុណភាព ការប្រើប្រាស់កម្មករ ការរចែកចាយ និងការគ្រប់គ្រងផលិតផលរបស់ពួកគាត់។ លើសពីនេះទៀត អគ្គនាយកដ្ឋានចំការកៅស៊ូអាចកែលំអរនូវបំណិនមូលដ្ឋានសម្រាប់កិច្ចការនាំចេញ និងទឹកចិត្តភាពជាសហគ្រិនជាក់ស្តែងរបស់សហគមន៍។

វិទ្យាស្ថានស្រាវជ្រាវចំការកៅស៊ូ បានរៀបចំគំរោងស្រាវជ្រាវបានច្រើនមកហើយដែលនៅក្នុងនោះបាននាំចូលឲ្យស្គាល់ក្លូនថ្មី និងត្រូវបានដាំសាកល្បងដោយផ្ទាល់នៅនឹងកន្លែងទៀតផង។ ជាមួយនឹងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូ និងអគ្គនាយកដ្ឋានចំការកៅស៊ូ អាចបង្កើនល្បឿននៃដំណើរការពេញលេញនៅក្នុងការចែកចាយនូវពត៌មាន

អំពីលទ្ធផលនៃការស្រាវជ្រាវដែលទទួលបានដល់អ្នកដាំកៅស៊ូដើម្បីយកទៅអនុវត្ត តាមរយៈរាជរដ្ឋាភិបាល ឬតាមរយៈការសហការ ឬការផ្តល់ហិរញ្ញប្បទានដែលមានការប្រាក់ទាបសំរាប់អ្នកដែលខ្វះខាតធនធាន។

ខ. គោលនយោបាយច្បាស់លាស់លើការអភិវឌ្ឍឧស្សាហកម្មកៅស៊ូដែលផ្តល់តំលៃបន្ថែមខ្ពស់ ជាពិសេសឧស្សាហកម្មផលិតកង់ឡាន កង់ម៉ូតូ គឺជាភាពចាំបាច់ដើម្បីជៀសវាងការតក់ស្លុតដែលមិនអាចគេចបានក្នុងពេលឆាប់ៗខាងមុខ នៅពេលដែលប្រទេសវៀតណាមនឹងកាត់បន្ថយសេចក្តីត្រូវការរបស់គេ ឬក៏បញ្ឈប់ការទិញកៅស៊ូពាក់កណ្តាលកែច្នៃពីកម្ពុជាដើម្បីលក់បន្តរទៅប្រទេសផ្សេងៗទៀត។ រាជរដ្ឋាភិបាលកម្ពុជាអាចជួយផ្តល់នូវការលើកទឹកចិត្តផ្សេងៗដល់អ្នកវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាអ្នកនៅក្នុងប្រទេសដើម្បីអភិវឌ្ឍវិស័យនេះដូចជាៈ

- បញ្ចុះអត្រាពន្ធនាំចូល ឬរំលោះពន្ធលើសម្ភារៈសំខាន់ៗដែលចាំបាច់ក្នុងការចាប់ផ្តើមបើករោងចក្រ
- រំដោះពន្ធ
- ផ្តល់ហិរញ្ញប្បទានជាមួយអត្រាការប្រាក់ទាប។

គ. កាត់បន្ថយការងារក្រដាស់ស្នាម(ចំនួនឯកសារ) ដើម្បីឲ្យអ្នកនាំចេញកៅស៊ូអាចបន្ថយនូវរយៈពេលនៃប្រតិបត្តិការ និងថ្លៃក្រោមតុ។ ទង្វើរនេះនៅទីបំផុតអាចធ្វើឲ្យកើនភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។

ឃ. ប្រសិនបើអាចទៅរួចគួរកាត់បន្ថយពន្ធលើការនាំចេញកៅស៊ូបន្ថែមទៀត។ ដូចគ្នានេះដែរ ប្រសិនជាអាច គួរកាត់បន្ថយ ឬលុបចោលនូវពន្ធលើថ្លៃបន្ថែមដែលបច្ចុប្បន្នមាន១០% លើអ្នកលក់កោស៊ូក្នុងស្រុក។ ទង្វើរនេះអាចនឹងជួយដោះស្រាយបញ្ហាខ្វះលំហូរសាច់ប្រាក់ដែលអ្នកនាំចេញតែងតែជួបប្រទះ។

ង. គួរផ្តល់ការពិចារណាជាអាទិភាពនូវការបង្កើតធនាគារអភិវឌ្ឍកសិ-ឧស្សាហកម្ម ពិព្រោះធនាគារនេះនឹងជួយរំញោចការអភិវឌ្ឍផលិតផលកសិកម្មទៅជាទំនិញប្រើប្រាស់។

## ៧. សេចក្តីសន្និដ្ឋាន

តំរូវការ និងតំលៃកៅស៊ូលើពិភពលោកទាំងមូលជួនឡើងជួនចុះ ប៉ុន្តែជាទូទៅនិន្នាការរបស់វាគឺកើនឡើង ដោយសារការកើនឡើងនៃការអភិវឌ្ឍរបស់ប្រទេសសំខាន់ៗមួយចំនួននាបច្ចុប្បន្ននេះ ជាពិសេសឥណ្ឌា និងចិន។

សក្តានុពលក្នុងការផលិតកៅស៊ូ ការនាំចេញ និងសក្តានុពលនៃការកែច្នៃទៅជាទំនិញប្រើប្រាស់ដែលឆ្លើយតបនឹងតំរូវការថ្ងៃអនាគត នៅតែបើកចំហរសម្រាប់ឲ្យប្រទេសកម្ពុជាអាចសម្រេចបាន នៅពេលណាដែលតួអង្គទាំងអស់ធ្វើការបង្រួបបង្រួមគ្នានូវធនធាន និងធ្វើការជាមួយគ្នាយ៉ាងជិតស្និតក្នុងជំហ៊ានដែលមានលក្ខណៈជាប្រព័ន្ធ និងស៊ីចង្វាក់គ្នា។ ដូច្នេះ គោលដៅនៃការលើកកំពស់កៅស៊ូដល់កំរិតទំនិញសេដ្ឋកិច្ចដើម្បីអភិវឌ្ឍ និងពង្រឹងកំណើនសេដ្ឋកិច្ចនៅកម្ពុជាគឺអាចធ្វើបាន។

**បណ្ឌិត ស៊ិន ម៉េងស្រ៊ុន**
ប្រធានអនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម
ECOSOCC

## ឯកសារយោង


1. Agence Française De Développement (AFD), (2009). Practical Handbook on Natural Rubber Export Procedures

2. Association of Natural Rubber Producing Countries (ANRPC), (March 2010). Natural Rubber Trends & Statistics.

3. Cambodia Development Research Institute (CDRI), (2002). Cambodia 's Annual Economic Review 2002.

4. Cambodia Rubber Research Institute (CRRI), (2009). Guideline for Cambodian Specified Rubber Certification.

5. Cambodia Rubber Research Institute (CRRI), (2009). Annual Technical Report 2008 – 2009.

6. Cambodia Rubber Research Institute (CRRI), (2009). Bulletin of the Cambodian Rubber Research Institute, N° 2, 2009.

7. Cambodia Rubber Research Institute (CRRI), (2010). Recommendations for Rubber Clones in Cambodia 2011 – 2013.

8. General Directorate for Rubber Plantation (2009). Rubber Stories of Cambodia.

9. Hang Chuon Naron (2009). Cambodian Economy: Charting the Course of a Brighter Future.

10. Hing Vutha & Thun Vathana (2009). "Agriculture Trade in the Greater Mekong Sub-Region: The Case of Cassava and Rubber in Cambodia, " CDRI Working Paper, Series N° 43.

11. Ministry of Agriculture, Forestry and Fisheries (MAFF). (Undated). Rubber Plantation in Cambodia.

12. Ministry of Agriculture, Forestry and Fisheries (MAFF). (2009). Annual Report 2008 – 2009.

13. Ministry of Agriculture, Forestry and Fisheries (MAFF). (2010). Annual Report 2009 – 2010).

14. Ministry of Commerce (2007). Cambodia 's Updated Trade Integration Strategy. DTIS 2007.

15. Ministry of Commerce (1996). Business & Investment Handbook in Cambodia.

16. National Institute of Statistics (2008). Statistical Yearbook of Cambodia 2008.

17. Saing Chan Hang (2009). The Asia-Pacific Research and Training Network on Trande (ARTNeT): Export Competitionners of the Cambodian Rubber Sector Relative to Other Greater Mekong Sub-Region Suppliers.

18. Sin Meng Srun (2009). An Overview of Agriculture in Cambodia,

# ការសម្ភាសន៍

1. Dr. Yin Song, (July 1st 2010), Director Cambodian Rubber Research Institute
2. H. E. Chan Tong Yves, (July 16, 2010), Secretary of State, MAFF
3. H. E. Ly Phalla, (July 20, 2010), General Director for Rubber Plantation